**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ.០០២.........ន. គ. ស ស.ជ.ណ

ថ្ងៃព្រហស្បតិ៍ ១០រោច ខែ បុស្ស ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មករា ឆ្នាំ២០២២

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ការអនុវត្តកាតព្វកិច្ចនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មកនិយ័តករគណនេយ្យនិងសវនកម្ម សម្រាប់សហគ្រាសដែលមិនរងសវនកម្មឯករាជ្យ

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគណនេយ្យនិងសវនកម្ម អនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្ដីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្ដីពីគណនេយ្យនិងសវនកម្ម និងក្នុងគោលបំណងជំរុញការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពព្រមទាំងធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុចំពោះគ្រប់ភាគីពាក់ព័ន្ធ **និយ័តករគណនេយ្យនិងសវនកម្ម**នៃ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** មានកិត្តិយសសូមជូនដំណឹងដល់ម្ចាស់សហគ្រាសទាំងអស់មេត្តាជ្រាបថា÷សហគ្រាសដែលមិនជាប់លក្ខខណ្ឌក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យ **មានកាតព្វកិច្ចត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួនមកនិយ័តករគណនេយ្យនិងសវនកម្ម ចាប់ពីការិយបរិច្ឆេទគណនេយ្យ២០២១ តទៅ។** ក្នុងការអនុវត្តកាតព្វកិច្ចខាងលើ សហគ្រាសត្រូវអនុវត្តតាមការណែនាំដូចខាងក្រោម÷

១. សហគ្រាសត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយអនុលោមតាមស្តង់ដាគណនេយ្យជាធរមានឱ្យបានរួចរាល់ក្នុងរយៈពេល៣(បី)ខែគិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យនីមួយៗ និងត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុនោះមក **ន.គ.ស.** មិនឱ្យហួសរយៈពេល ៣ (បី) ខែ និង ១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យនីមួយៗ។

២. សហគ្រាសត្រូវប្រើប្រព័ន្ធអនឡាញ (E-filing system) របស់ **ន.គ.ស.** ដើម្បីដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក និយ័តករគណនេយ្យនិងសវនកម្ម និងត្រូវបង់កម្រៃសេវាសាធារណៈសម្រាប់ការទទួលរក្សាទុករបាយការណ៍ហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ០០១ អ.ស.ហ.ប្រ.ក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ស្ដីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម។

***"ការខកខាន ឬ ការយឺតយ៉ាវមិនបានអនុវត្តកាតព្វកិច្ចតាមការកំណត់ខាងលើ សហគ្រាសត្រូវរងទោសទណ្ឌដូចមានចែងនៅក្នុងអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ស្ដីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្ដីពីគណនេយ្យនិងសវនកម្ម"។***



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីមែល : info@acar.gov.kh
ទូរស័ព្ទ ៨៥៥ - ២៣ ៨៨២ ១១១
Phone: 023 882 111

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមន្ត្រីនៃ **ន.គ.ស.** តាមរយៈទូរស័ព្ទនិងតេឡេក្រាមលេខ÷០៩៣ ៩៧៩ ១៩២/ ០៧០ ៩២៩ ២៣៧/ ០៨៥ ៤៤៤ ៤៨៨។

**និយ័តករគណនេយ្យនិងសវនកម្ម** ជឿជាក់យ៉ាងមុតមាំថា ម្ចាស់សហគ្រាសទាំងអស់នឹងអនុវត្តកាតព្វកិច្ចនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.** តាមពេលកំណត់ និងបានគ្រប់សហគ្រាស។

អាស្រ័យហេតុនេះ សូមម្ចាស់សហគ្រាសទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ចាប់ពីពេលនេះតទៅ។

**អគ្គនាយក**

**ប៊ូ ថារិន**

**ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សូមចូលរួមក្នុង Telegram Channel របស់ និយ័តករគណនេយ្យនិងសវនកម្ម**